២

ម៉ែណមលើកដៃគោះទ្វារដែលបើកចំហស្រាប់ពីរតុកសិន ទើបដើរចូលទៅក្នុងបន្ទប់ការិយាល័យ។ លោកបុញ្ញវន្តកំពុងតែអង្គុយពិនិត្យបញ្ជីរឯកសារផ្សេងៗឡើងមួយគំនរនៅលើតុ។ ម៉ែណមដាក់ថាសដែលគាត់កាន់មកតាមខ្លួនទៅលើតុទំនេរមួយនៅជិតនោះ ហើយលាន់មាត់បន្ទោសស្រាលៗ "ទើបតែអាចក្រោករួច អ្នកប្រុសខំប្រឹងធ្វើការទៀតហើយ ... ចាំញ៉ាំអាហារព្រឹកនិងញ៉ាំថ្នាំហើយសិនក៏មិនបាន"
អ្នកប្រុសយើងបិទសំណុំឯកសារដែលកំពុងអាន ហើយងើបមកអង្គុយនៅកូនតុដែលម៉ែណមទើបដាក់ថាសអាហារចុះទៅមុននេះ។ គេបន្ទឺសួរ "តើនាងផ្ការ្ចួចយ៉ាងណាទៅហើយ? សូមម៉ែជួយមើល ជួយឱ្យគេសម្របខ្លួននៅទីនេះតាមសម្រួលផង"
"ឃើញក្រោកចុះទៅដើរកំសាន្តនៅក្នុងសួនតាំងពីព្រលឹម ... មុននេះឃើញជជែកចរចានិងជួយថែសួនជាមួយនាយដុន ... អ្នកប្រុសជឿមែនទេ ថានាងនេះជាចៅស្រីរបស់លោកប្រុសសុទ្ធិគុណ?"
បុញ្ញវន្តគ្រវីក្បាល "មិនប្រាកដទេ មានតែចាំមើលសិនទៅ ការពិតគង់តែលេចចេញមកទេ ..."
ម៉ែណមដកដង្ហើមធំ "បើរាប់ទាំងលើកនេះទៀត គិតទៅមានអ្នកមកប្រកាសខ្លួនជាកូនចៅលោកប្រុសសុទ្ធិគុណ១៣ដងហើយ ... ឱ មនុស្សអើយមនុស្ស ដើម្បីមាសប្រាក់ លាភសក្តារ: អំពើឆរបោកអ្វីក៏ហ៊ានប្រព្រឹត្តដែរ ..."
បុញ្ញវន្តងើបមុខសម្លឹងស្លឹកដូងនៅខាងក្រៅបង្អួច ពោលតិចៗ "តែនាងម្នាក់នេះមានលក្ខណៈប្លែកពីពួកមុនៗ ដែលខ្លះមកទាមទារមរតកឆៅៗស្រស់ៗតែម្តង ... នាងនេះប្រកាសថាមិនចង់បានអ្វីទេ សុំតែតំណែងការងារតូចតាចមួយក្នុងក្រុមហ៊ុនប៉ុណ្ណោះ"
"មិនដឹងថានៅពីក្រោយសំណូមពរតូចតាចនោះ មានលាក់គំនួចអ្វីធំដុំឬអត់ទេ ... ម៉ែមិនលាក់នឹងអ្នកប្រុសទេ ... ពេលឃើញមុខនាងភ្លាម ម៉ែព្រឺក្បាលសំពោងតែម្តង ...

នាងមានមុខមាត់ដូចលោកប្រុសសុទ្ធិគុណខ្លាំងណាស់ ...ម៉ែខ្លាចតែមានគេជ្រើសរើសនាងនេះយកមកឱ្យជ្រៀតចូលក្រុមហ៊ុនអ្នកប្រុសក្នុងចេតនាមិនល្អអ្វីម្យ៉ាង"

"ម៉ែកុំព្រួយអី ... បើគេជាមនុស្សអាក្រក់ខ្ញុំមិនឱ្យគេរួចខ្លួនទេ តែបើគេជាសាច់ឈាមរបស់លោកអ៊ំសុទ្ធិគុណ ខ្ញុំនឹងទំនុកបម្រុងគេឱ្យល្អបំផុត ដើម្បីឱ្យវិញ្ញាណក្ខន្ធលោកយាយលោកតាបានស្ងប់ ... ក្នុងពេលនេះ សុំម៉ែណមណែនាំឱ្យបាវបម្រើទាំងអស់គោរពគេតាមឋានៈ សុំប្រគល់ប្រាក់កាសឱ្យគេទុកចាយវាយខ្លួនឯងខ្លះ ... ថ្ងៃនេះ សុំម៉ែជួយនាំគេទៅផ្សាររកទិញសម្លៀកបំពាក់ឱ្យបានសមរម្យផង"

ម៉ែណមឆ្លើយទទួលបញ្ជានិងនៅចាំគាល់ក្បែរទាល់តែអ្នកប្រុសបរិភោគអាហារពេលព្រឹកនិងញ្ញាំថ្នាំហើយ ទើបគាត់លើកថាសចេញទៅវិញ។

នាងផ្កាក្រូចកំពុងតែរៀនកាត់ស្មៅជាមួយបុរសអ្នកថែសួនឈ្មោះដុន ដែលនាងទើបចងមិត្តថ្មីៗ ស្រាប់តែមានទាសីម្នាក់មកតាមឱ្យទៅជួបម៉ែយាយណម។ ធីតាហុចកន្ទ្រែកាត់ស្មៅឱ្យទៅបុរសចំណាស់ប្រមាណជាជាងពាក្យ៣ឆ្នាំវិញ ហើយក្រោកឈរ តែមុននឹងចាកចេញ នាងឆ្លៀតពោល "អរគុណហើយណា៉ ពូដុន ដែលបានជួយបង្រៀនខ្ញុំឱ្យចេះកាត់ស្មៅ ចាំមានពេលទំនេរ ខ្ញុំមករៀនជាមួយពូទៀត"

ពូដុនញញឹម "បាទ៉ អញ្ជើញចុះនាង"

ពេលមានតែពីរនាក់នៅក្នុងបន្ទប់ ម៉ែណមបានដកក្រដាសប្រាក់មួយដុំចេញមកហុចឱ្យនាងផ្កាក្រូច "នេះប្រាក់មួយពាន់រៀល លោកប្រុសប្រគល់ឱ្យនាងទុកគ្រាន់ចាយវាយផ្ទាល់ខ្លួន"

នារីបើកភ្នែកធំៗ ហើយគ្រវីក្បាល "នាងខ្ញុំមិនទទួលទេ ... សូមម៉ែយាយជួយជម្រាបលោកប្រុសផង ថានាងខ្ញុំមិនទទួលប្រាក់ទទេៗ ដោយមិនបានបញ្ជេញកម្លាំងឡើយ"

ម៉ែណមចងចិញ្ចើម "ខ្ញុំធ្វើការក្រោមបញ្ជាលោកប្រុសតែម្នាក់ប៉ុណ្ណោះ ... បើនាងចង់តវ៉ាជាមួយលោកយ៉ាងណាៗ មេត្តានាងទៅជជែកវែកញែកជាមួយលោកចុះ ខ្ញុំមិនបានធ្វើជាអ្នកនាំពាក្យឱ្យនាងទេ!"

តរុណីលើកដៃសំពះ "នាងខ្ញុំសុំទោស នាងខ្ញុំគ្មានចេតនាធ្វើឱ្យម៉ែយាយអាក់អន់ចិត្តទេ ... តែជីដូននិងម្តាយនាងខ្ញុំធ្លាប់ប្រដៅថាកុំឱ្យចង់បានទ្រព្យអ្នកដទៃដោយមិនបាន

បញ្ជេញកម្លាំងអ្វីសោះ ... ប្រាក់នេះនាងខ្ញុំមិនទទួលទេ! បើលោកប្រុសបន្ទោស នាងខ្ញុំសុខចិត្តទទួលកំហុស"

ប្រមាណជា៣០នាទីក្រោយមក មានអ្នកមកតាមនាងផ្កាក្រូចទៅជួបលោកប្រុស នៅក្នុងកូនបណ្ណាល័យ។ ពេលយុវតីចូលទៅដល់ លោកបុញ្ញវន្តកំពុងតែឈរក្រពាត់ដៃ បែរមុខចេញទៅមាត់បង្អួច។ ចាប់ប្រាក់ដែលម៉ែណមប្រគល់ឱ្យនាងមុននេះ កំពុងដេកសំដិលខ្លួននៅលើតុ។ នារីឈរស្ងៀម សម្លឹងប្រមុខគេហដ្ឋានពីក្រោយខ្នង អស់មួយខណៈ ទើបដាច់ចិត្តស្រដី "នាងខ្ញុំមកដល់តាមបញ្ជាហើយ លោកប្រុស"

លោកប្រុសបែរមុខមក ហើយវាចាចូលសាច់ការភ្លាម "ន៎ុះ ប្រាក់សម្រាប់នាងចាយ រ៉ាយផ្ទាល់ខ្លួន ទម្រាំនាងមានប្រាក់ខែ ... ពួកយើងបានសម្រេចគ្នាកាលពីយប់មិញរួចហើយ ថានាងត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ ... មនុស្សនៅក្រោមការគ្រប់គ្រងរបស់ខ្ញុំ ត្រូវស្តាប់បង្គាប់ខ្ញុំ ... មនុស្សរបស់ខ្ញុំត្រូវមានបែបបទ មានជីវភាពសមរម្យ ... នាងយកប្រាក់នោះទុកចុះ ហើយត្រូវរៀបខ្លួនទៅផ្សារជាមួយម៉ែណម ដើម្បីទិញសម្លៀកបំពាក់ថ្មីសម្រាប់ផ្ទាស់ប្តូរ និងជួយទិញម្ហូបអាហារគាត់ផង បើនាងរអៀសខ្លួនថាមិនចង់ទទួលប្រាក់ដោយមិនបានបញ្ជេញកម្លាំង ... បែបនេះមែនទេ ទើបនាងស្ទុះស្ទាទៅជួយកាត់ស្មៅនាយដុនទាំងព្រឹក?"

នារីឈ្ងោកមុខ "តើការដែលនាងខ្ញុំទៅកាត់ស្មៅ ជាអំពើខុសឆ្គងដែរទេ?"

"មិនខុសឆ្គងអ្វីទេ ... តែនាងត្រូវចាំថា នាងរស់នៅជាមួយខ្ញុំមិនមែនក្នុងនាមអ្នកបម្រើក្នុងផ្ទះឡើយ ហេតុនេះនាងត្រូវរៀបចំកិរិយាឫកពារឱ្យសក្តិសមតាមឋានៈ!"

ផ្កាក្រូចងើបមុខសួរ "តើឋានៈជាអ្វីទៅ?"

"ក្នុងពេលនេះ គឺឋានៈជាភ្ជៀវរបស់ខ្ញុំ ... ពួកបាវបម្រើត្រូវគោរពនាងដូចគេគោរពខ្ញុំដែរ ... លើកលែងតែបន្ទប់គេងរបស់ខ្ញុំ បន្ទប់ធ្វើការរបស់ខ្ញុំ និងបន្ទប់ដំណេកគេដទៃ នាងអាចចេញចូលនិងប្រើប្រាស់វត្ថុផងទាំងពួងក្នុងគេហដ្ឋាននេះដោយសេរី ... តើនៅមានចម្ងល់អ្វីទៀតទេ?"

"ចាស់ គ្មានទេ" នារីឆ្លើយដោយទម្លាក់មុខទៅវិញ។

"បើអញ្ជើងស្តាប់គ្នាបានហើយ ... យកប្រាក់ទៅទុកដាក់ចុះ ហើយឆាប់ទៅតាមម៉ែ

ណម កុំឱ្យមនុស្សចាស់ពិបាករង់ចាំយើងជាក្មេង"
នារីដើរចូលមកលើកប្រាក់ពីលើតុទាំងមុខមិនសូវរីក។ នាងលើកដៃសំពះ បន្ទីវាចា អរគុណ ហើយចាកចេញទៅរកម៉ែណមជាបន្ទាន់។
ម៉ែណមបាននាំនាងផ្កាក្រូចឡើងឡានទៅផ្សារកំពត ចូលហាងសម្លៀកបំពាក់ទំនើប ជ្រើសរើសទិញសម្លៀកបំពាក់ឱ្យនាងជាច្រើនសម្រាប់ មានសំពត់ ខោអាវសម្រាប់ពាក់នៅផ្ទះនិងសម្រាប់ពេលចេញក្រៅ។ បន្ទាប់មកទើបពួកគេចូលក្នុងផ្សារធំរកទិញម្ហូបអាហារម្តង។ ទីផ្សារមានសភាពអ៊ូអរ ពោរពេញដោយសំលេងនិងមនុស្សម្នាពពាក់ពពួនទាំងអ្នកលក់ទាំងអ្នកទិញ។ អ្នកលក់ខ្លះដាក់តាំងទំនិញរបស់ខ្លួនលើវានឬស្សីឬឈើក្តារផុតពីដី ខ្លះដាក់តាំងលើកន្ទេល ជាលឬល្អីផ្ទាល់ដីតែម្តង ... បន្ទែបង្ការត្រីសាច់ស្រស់ៗ មានពោរពាស។ ផ្កាក្រូចសង្កេតឃើញថា ម៉ែណមមិនទិញត្រីរស់ទេ គាត់ដើរអ៊ីតដើរឈ្ងោករកមើលឃើញមានត្រីងាប់ទើបគាត់ចូលទៅចាប់លើកត្រលប់ចុះឡើង តែដោយគុណភាពមិនសូវល្អគាប់ចិត្ត គាត់ក៏បន្តដំណើរទៅមុខទៀត គ្រាន់តែគាត់ដើរចេញភ្លាម អ្នកលក់ខ្លះចាប់ត្រីរ៉ស់ ត្រីអណ្តែង ត្រីក្រាញ់ បង្ករ ដ៏ធំ ធាត់ទ្រលុកៗ មកវាយក្បាល កាច់ក១ស១ ប្រកាច់ត្រិលៗ មួយរំពេច រួចនាងយួនម្នាក់ ស្រែកអំពាវនាវដោយសំលេងប៉ែ២ាំ២ាថា "ម៉ែយាយអើយ ... មានអាតែសាកហើយ ..." អ្នកលក់ត្រីក្បែរ១ៗនោះក៏ស្រែកឱ្យរញ្ជ្ញីថា "ខ្ញុំក៏មានដែរ! ... ខ្ញុំក៏មានដែរ! ... សុទ្ធតែស្រស់ៗ ... ទើបតែងាប់ម៉ុញ១ៗនេះឯង! ..."
ម៉ែណមត្រលប់ក្រោយ រើសត្រីតាយសាក ត២ាន្ទ្ធទិញយកអស់ជាច្រើនគីឡូ។ ម៉ែណមនិងផ្កាក្រូចមិនបាច់កាន់ មិនបាច់យួរ២ាវ៉ាន់អ្វីទេ ព្រោះមានបុរសគូលីពីរនាក់ដើរតាមចាំលីកន្ត្រកដាក់ទំនិញជាប់ជាប្រចាំ។
ពេលមកដល់ផ្ទះឯកែបវិញ ផ្កាក្រូចបានជួយធ្វើម្ហូបម៉ែណមទៀត។ ថ្ងៃបើស្ត្រីចំណាស់មិនមាត់ តែក្នុងចិត្តគាត់លួចសរសើរចរិតឧស្សាហ៍ រហ័សរហួន ឆាប់យល់ការណ៍របស់នារីក្មេងនេះជាពន់ពេក ហើយគាត់ក៏លួចព្រួយ ព្រោះមិនដឹងថានាងម្នាក់នេះមានចិត្តលោភលន់ មានបំណងអាក្រក់ល្អយ៉ាងណាទេ ...។

ផ្កាក្រូចបានមកស្នាក់នៅក្នុងវីឡាលំហែររបស់លោកសេដ្ឋីបុញ្ញវន្តបានមួយសប្តាហ៍ហើយ ក្រៅពីលោកប្រុសនិងម៉ែណមដែលនៅហៅយុវតីយើងថានាងៗដដែល បាវបម្រើងទៀតសុទ្ធលំនិនកាយនិងហៅនាងថា **អ្នកនាងៗ** ពេលណាពួកគេចរចាជាមួយផ្កាក្រូច។ ផ្កាក្រូចក៏ហៅពួកគេថាបង ឬមីង ពូ ទៅតាមវ័យពួកគេវិញ។

ផ្កាក្រូចត្រូវបរិភោគអាហារជាមួយលោកបុញ្ញវន្តជារៀងរាល់ល្ងាច។ ក្រៅតែពីសាកសួរនាងតិចតួចពីជីវភាពប្រចាំថ្ងៃ លោកប្រុសមិនដែលដេញដោលផ្កាក្រូច មិនដែលនិយាយលេងសើច មិនដែលញញឹម ... ឱ ស្នាមញញឹម ... ផ្កាក្រូចតែងលួចសង្ឃឹមថានាងនឹងបានឃើញស្នាមញញឹមរបស់លោកប្រុសនៅពេលណាមួយ ... គេជាបុរសរូបសង្ហា មុខមាត់ក៏ស្អាតបាតដូចទេវបុត្រ តែទាស់កិរិយាសោះកក្រោះហួសនិស្ស័យ មុខស្ទើធេងជាប់រហូត ដូចគេពាក់ស្រោមច្នៃចេញពីលោហធាតុ ... ផ្កាក្រូចចង់ដឹងណាស់ថាតើលោក នុត បុញ្ញវន្ត ម្នាក់នេះចេះខឹង ចេះកើតទុក្ខ ចេះសប្បាយដូចគេ ដូចឯងដែរឬទេ?

ដោយពុំសូវមានការងារធ្វើ ក្រៅតែពីទៅផ្សារនិងជួយធ្វើម្ហូបម៉ែណម ជួយស្រោចផ្កាពូដុន ជួយលាងឡានពូសឹមនិងអ៊ុំដេត ផ្កាក្រូចក៏ចូលបណ្ណាល័យលោកបុញ្ញវន្ត រើសរកស្សៀវភៅប្រលោមលោកផ្សេងៗមកអាន។ ដំបូងនាងយកស្សៀវភៅចេញទៅអានត្រឹមតែក្នុងសួនច្បារក្នុងផ្ទះទេ តែក្រោយមកក៏បែកប្រាជ្ញាខ្ជីកង់ពូដុន ជិះចេញទៅលំហែរកាយនៅតាមមាត់សមុទ្ររាល់ពេលរសៀល។

ផ្កាក្រូចទើបតែអានបញ្ចប់រឿងផ្កាស្រពោនរបស់អ្នកនិពន្ធ **ន្ហូ ហាង** ...។ នាងបិទស្សៀវភៅ លើកដៃជូតទឹកភ្នែក។ នាងបានអានរឿងនេះប្រហែល១០ដងមកហើយ តែអានលើកណាក៏នាងនៅតែយំសោកស្រណោកស្រណោះជាមួយតួអង្គវិធាវីនិងប៊ុនធឿនមិនដែលខាន។ ផ្កាក្រូចមានចំណូលចិត្តអានប្រលោមបែបមនោសញ្ចេតនានិងទស្សនវិជ្ជា មិនថាប្រលោមលោកជាភាសាខ្មែរ បារាំង អង់គ្លេស ឬថៃទេ ឱ្យតែឃើញគឺស្រវាំទំពារលេបដាក់ក្នុងអារម្មណ៍ទាំងអស់ លុះមានពេលទំនេរ ជាពិសេសពេលរៀបនិទ្រាលង់លក់ នារីក៏ខ្ជាក់មនោរម្មណ៍ដ៏ស្រើបស្រាលលន្ហង់លន្ហោចទាំងអស់នោះមកចម្រាញ់យករសជាតិពិសេស យកមនោសញ្ចេតនាក្នុងសាច់រឿងមកប្រលែង

លេងនឹងដួងវិញ្ញាណជាថ្មី ប្រៀបបីដូចគោរើស្មៅមកទំពារអ្ៀងដូច្នោះដែរ ។
ផ្កាក្រូចខ្សឹតសំបោរ ដាក់ស្បៃវ៉ាភ្ជាចូលទៅក្នុងសំពៀតកំណាត់សំពត់ដែលនាងស្ពាយ ឆ្សៀងជាប់ខ្លួន ក្រោកឡើងមកទាញទោចក្រយានដែលនាងដាក់ផ្ទែកនឹងគល់រុក្ខជាតិ អូសជំនិះចេញពីឆ្នេរខ្សាច់មាត់ទឹក តម្រង់មករកផ្លូវចាក់កៅស៊ូវិញ ។ ធីតាធាក់កង់ បណ្តើរ បណ្តែតអារម្មណ៍រវើរវាយរាយមាយនឹកដល់ស្រុកកំណើតឯបាត់ដំបងបណ្តើរ ទឹកអូរ ... រាលស្រែ ... ចម្ការក្រូច ... ។ មកដល់ផ្លូវកោងព័ទ្ធភ្នំ ស្រាប់តែទោចក្រ យានឯងក្រមុំបានពើបប្រទះនឹងរថយន្តដែលកំពុងបោះពួយលឿនស្តើមកពីមុខ ។
រថយន្តខំចាប់ប្រ្ចាំងសង្ឆៀតកង់នឹងថ្នល់លាន់សូរឡើងស្រក្យៀវត្រចៀក ... នារីខំ បំបែរយានគេចទៅខាងស្តាំដៃ តែជាអកុសល យានតូចធំទាំងពីរនៅតែទង្គិចគ្នាប្រាវ! ផ្កាក្រូចខ្ចាតចេញពីកង់ទៅដួលស្ព្ចាបនៅក្បែនផ្លូវ ។ ម្ចាស់រថយន្តបើកទ្វារចេញមក ក្រៅ តែគេមិនរវល់យកភ្នែកមើលអ្នករងគ្រោះទេ បែរជាស្ទុះស្ទ្ចាមកស្ទ្ចាបពិនិត្យ មើលថាតើមុខឡានគេដាច់ដោចរលាត់ថ្នាំត្រង់ណាខ្លះ ។ ផ្កាក្រូចខំក្រោកឡើង ថ្ងូ រអូយ៎ៗ ព្រោះជង្គង់ទាំងពីរនិងកែងដៃស្តាំដាច់ឈាមរហាម ។ ម្ចាស់រថយន្តងាកមក ស្រែកដាក់អ្នករងគ្រោះ "នាងឯងខ្វាក់ភ្នែកទេឬ ទើបធាក់កង់ភ្លើ១មកជល់ឡាន របស់យើង?!"
ផ្កាក្រូចកំពុងតែឈឺនិងក្តៅចិត្តស្រាប់ផង ក៏ស្រែកគំហកដាក់វិញ "អ្នកឯងហ្ម៉ឹងហើយ ភ្លើផងខ្វាក់ផង មនុស្សទាំងមនុស្សចេះបើកឡានមកបុកទាំងរស់ទៅកើតដែរ អូយ៎"
ម្ចាស់យានដើរចូលមកជិតនារីរងគ្រោះ "អ៊ំពល់ទុក្ខមែន យើងកំពុងតែប្រញ្ជាប់ផង តើត្រូវត្រង់ណាខ្លះដែរ?"
ផ្កាក្រូចលើកកែងដៃមកមើល "ចង្រៃមែន ... អូយ៎ ... ដាច់សាច់ទាំងដុំ ... "
"នៅនិយាយបានប៉ប៉ោចដូចនេះ មុខតែមិនធ្ងន់ធ្ងរទេ ... គ្រាន់តែរលាត់ស្បែកតិចតួច មិនស្លាប់ទេ កុំខំមាយាពេក ... ត្រូវអរគុណយើងទៅ បើយើងមិនរ៉ាសជាន់ប្រ្ចាំង ទាន់ទេ នាងឯងបានទៅលេងស្ថានថ្មីទៅហើយ!"
ផ្កាក្រូចបើកភ្នែកធំ១ ក្រោកឈរចង្អុលមុខ "យីអើ នេះបានចំជាមនុស្សគម្រក់! ... បើកឡានបុកគេហើយ ចង់ឱ្យគេសំពះអរគុណទៅវិញឬ?"

"ន៏ កុំញ៉ៃត១ពេក ..." គេលូកហោរ៉ៅខោទាញកាបូបលុយចេញមក "ហក់ណេះ យកទៅ ១00រៀល សម្រាប់ជួសជុលកង់និងទិញថ្នាំក្រហមលាបរបួស" គេដកយកក្រដាសប្រាក់មួយរយរៀលមួយសន្លឹកចេញមកបុចឱ្យនារីរងគ្រោះ។
ផ្កាក្រូចងាកមុខចេញ "មិនត្រូវការទេ!"
ម្ចាស់រថយន្តបើកភ្នែកធំ១ "ន៏នាង កុំចង់ធ្វើឫកហួសហេតុពេក ... នៅឈរបានឆ្ពោតដូច្នេះកុំចង់ទារជំងឺចិត្តច្រើនឱ្យសោះ ... នេះយើងមិនទាមទារឱ្យនាងឯងសងថ្លៃខូចខាតឡានយើង គឺសំណាងណាស់ទៅហើយ!"
ផ្កាក្រូចងាកមកសម្លក់ "ទុកប្រាក់សម្អុយរបស់លោកឯងវិញទៅ ខ្ញុំមិនត្រូវការទេ! ខ្ញុំចង់ដឹងណាស់ បើខ្ញុំបើកឡានបុកលោកឯងឱ្យដួលត្រលប់ត្រលិន ហើយបុចប្រាក់មួយរយរៀលសងជំងឺចិត្តវិញ តើលោកសប្បាយចិត្ត អរកខ្ចិបកខុបទទួលយកហើយមែនទេ?"
បុរសចងចិញ្ចើម "យី នាងនេះចំជាសាំតាប៉ែ"ម៉ែន ... យើងគ្មានគំនិតមកបើកឡានបុកនាងឯងឱ្យស៊ីយបែបនេះទេ ... មួយរយរៀល ... យកមិនយកស្រេចតែនាងឯងទេ!" ពោលចប់គេបោះលុយទៅលើដី ត្រលប់ខ្លួនដើរទៅចាប់លើកកង់បោះចេញពីមុខឡាន ហើយចូលក្នុងរថយន្តបើកចេញវឹងទៅ។
ផ្កាក្រូចលោតផ្ទោត១ទៅលើកកង់ឡើងទាំងខ្លួនញ័រទទ្រើក ...។ កង់ខាងមុខរបស់ទោចក្រយានវ៉ៃចឡើងពៀច ចង្កូតយានក៏វ៉ៃចក្រងេវ មិនអាចជិះធ្វើដំណើរតទៅទៀតបានឡើយ។ ផ្កាក្រូចទាញសម្រួលកកង់ឱ្យត្រង់បន្តិច ហើយអូសយានចូលមករើសក្រដាសប្រាក់ដាក់ទៅក្នុងសំពៃត ទើបធ្វើដំណើរត្រលប់ទៅផ្ទះវិញ។ ម៉ោងជិត ៥ល្ងាចទើបផ្កាក្រូចបានទៅដល់ផ្ទះ។ ឃើញនាងដើរជ្ងាំងខ្ទើក១ ឈាមរហេមរហាម អ្នកសង់កំព្រូកចូលដល់បរិវេណភូមិគ្រឹះ មនុស្សម្នាផ្ញើលឆោឡោមកសួរនាំ។
ម៉ែណមមានមុខស្លេក នាំនាងទៅលាងរបួសជាបន្ទាន់។ ផ្កាក្រូចពោលរៀបរាប់ទាំងកំហឹងថា "គឺមានអាតាបុ"ឆ្ពូតទុកសក់វ៉ែង ទុកពុកមាត់ស្រមូមដូចស្ងាម្នាក់ រ៉ាបើកឡានមកបុកខ្ញុំ ..."
មនុស្សនៅជុំវិញនាងលាន់មាត់ "សក់វ៉ែង? មុខស្រមូម?"

ផ្កាក្រូចពោលបន្ត "ស្តាយណាស់ ខ្ញុំភ្លេចមើលលេខឡានវា ... កុំអីប្តឹងឱ្យប៉ូលីសចាប់ដាក់គុកឱ្យស៊ីបាយក្រហមឱ្យសមមុខវាម្តង ... ខ្ញុំគ្រាន់តែចាំថា ឡានរបស់វាគឺម៉ាករ៉ែណូលត៍ ពណិស ..."

"ឡានពណិស?" អ្នកឯទ្យៀតលាន់មាត់ជាថ្មី។ ផ្កាក្រូចរវល់តែឈឺរបួស មិនបានចាប់អារម្មណ៍និងសម្តីមនុស្សជុំវិញទេ ខំតែខាំមាត់ថ្ងូរតិចៗពេលម៉ែណមជូតអាល់កុលសម្អាតលើមុខរបួស។

ពេលម៉ែណមរុំរបួសឱ្យផ្កាក្រូចរួច គាត់ចេញទៅបាត់។ ផ្កាក្រូចខំយោងខ្លួនក្រោកឈរឡើង។ នាងបម្រើម្នាក់ខំស្ទុះមកទប់នារីយើង "អ្នកនាងចង់ទៅណា?"

"ខ្ញុំចង់ទៅចង្រ្កាន ជួយធ្វើម្ហូបម៉ែយាយ ណ៉ាបងម៉ាប់"

"ពុទ្ធោ យោងតែអាត្មាមិនចង់រួចផង តើទៅធ្វើម្ហូបអីទ្យៀត ... ទៅបន្ទប់អ្នកនាងសម្រាកទៅប្ម ចាំបងជូនទៅ?"

រំពេចនោះលោកបុញ្ញវន្តចូលមកដល់ល្មម ដោយមានម៉ែណមដើរតាមពីក្រោយ។ គ្រាន់តែក្រលេកមើលនាងផ្កាក្រូចមួយត្រួស លោកប្រុសងាកទៅបញ្ជានាងម៉ាប់ "នាងទៅប្រាប់នាយសឹមឱ្យរៀបចំឡាន!"

នាងម៉ាប់លំឱនកាយ រត់ចេញទៅភ្លាម។

លោកប្រុសងាកមករកផ្កាក្រូច "នាងដើររួចទេ?"

"ចាស់ រួចលោកប្រុស" ផ្កាក្រូចឈរតោងបង្អែកកៅអី ញ័រជើងតិចៗ។

លោកប្រុសងាកទៅរកស្ត្រីចំណាស់ម្តង "ម៉ែណម ជួយគ្រាហ៍នាងទៅក្រៅផង"

នារីក្មេងងើបមុខសួរ "តើនាំនាងខ្ញុំទៅណា លោកប្រុស?"

"ទៅពេទ្យ" បុរសឆ្លើយយ៉ាងខ្លី។

ផ្កាក្រូចប្រកែក "នាងខ្ញុំមិនធ្ងន់ធ្ងរទេ គ្រាន់តែរលាត់ស្បែកតិចតួចប៉ុណ្ណោះ មិនចាំបាច់ទៅពេទ្យទេ! ..."

លោកប្រុសតបដោយមុខស្មើធេងដដែល "ពេលមនុស្សចាស់សម្រេចចិត្តអ្វី នាងត្រូវចេះស្តាប់តាមខ្លះទៅ ... កុំពូកែប្រឆាំងជំទាស់តាមតែគំនិតខ្លួនពេក"

ពោលហើយគេដើរចេញទៅ។ ម៉ែណមក៏ចូលមកជួយទប់ផ្កាក្រូច ដើរចែវគាស់ៗទៅ

តាមក្រោយលោកប្រុស។ នៅមុខផ្ទះ មានរថយន្តម៉ែរសឺដែសពណិខ្មៅដ៏ធំសង្ហាមួយ ចតចាំជាស្រេច។ ពូសឹមស្ទុះមកបើកទ្វារយានខាងក្រោយ ម៉ែណមជួយបញ្ចូលផ្កាក្រូចទៅលើកៅអីពូករថយន្ត។ ឃើញចៅហ្វយប្រុសដើរទៅចំហ្យៀងរថយន្តម្ខាងទៀត ពូសឹមខំស្ទុះត្រុនៗទៅបើកទ្វាររថយន្តឱ្យបានមុន។ លោកប្រុសចូលមកអង្គុយទន្ទឹមនាងផ្កាក្រូច។ ម៉ែណមចូលទៅអង្គុយទន្ទឹមពូសឹម។ ពូសូហ្វ័រក៏បំបរយានឆ្ពោះទៅកាន់ទីកន្លែងកំណត់តាមបញ្ជាលោកប្រុសភ្លាម។

លោកបុញ្ញវន្តបាននាំផ្កាក្រូចទៅគ្លីនីកបារាំងមួយ ឱ្យគេពិនិត្យរបួសនាងយ៉ាងយកចិត្ត ទុកដាក់បំផុត ថែមទាំងឆ្លុះកាំរស្មីអ៊ីកស៍មើល ក្រែងមានបាក់បែកស្រាំឆ្អឹងត្រង់ណាខ្លះ តាំងពីក្បាលដល់ជើង។ ក្រោយពីបានការបញ្ជាក់ច្បាស់ពីដុកទ័របារាំងថាផ្កាក្រូចពុំមានរបួសអ្វីធ្ងន់ធ្ងរទេ ទើបលោកប្រុសយើងអស់ចិត្ត នាំផ្កាក្រូចមកផ្ទះវិញ។

ដើម្បីកុំឱ្យផ្កាក្រូចពិបាកចុះឡើងជណ្តើរទៅបន្ទប់ដំណេករបស់នាងនៅជាន់ខាងលើ លោកបុញ្ញវន្តបានឱ្យគេរៀបចំបន្ទប់ខាងក្រោមមួយឱ្យនាងស្នាក់នៅ ព្រមទាំងឱ្យម៉ែណមគេងកំដរនាងពេលយប់ៗផងព្រោះក្រៅពីដររបួសដើរស្ទើរមិនរួច ផ្កាក្រូចគ្រុនស្រៀវស្រាញអស់ពីរថ្ងៃ ទោះជានាងបានលេបថ្នាំបំបាត់ការឈឺចាប់យ៉ាងទៀងទាត់ហើយក៏ដោយ។ គ្រូពេទ្យថាអាចបណ្តាលមកពីនាងលោះព្រលឹងពេលមានគ្រោះថ្នាក់នោះឯង។

បាននៅកាន់តែជិតគ្នា ស្ត្រីចាស់ក្មេងទាំងពីរមានឱកាសបានសួរនាំគ្នាពីនេះពីនោះកាន់តែច្រើនឡើង។ ពេលផ្កាក្រូចញញឹមម្តងៗ ម៉ែណមតែងសម្លឹងមើលមុខនាងស្ទើរភ្លឹក ទម្រាំតែភ្សាក់ខ្លួនងាកមុខចេញទៅវិញ។